# សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

# សារលិខិត

## សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
## ថ្លែងក្នុងទិវាជាតិអាហារូបត្ថម្ភ លើកទី៤ (៦ វិច្ឆិកា ២០១៤ - ៦ វិច្ឆិកា ២០១៧)
## ក្រោមប្រធានបទ "ផលិត និងបរិភោគអាហារចម្រុះសម្បូរជីវជាតិ ដើម្បីសុខភាពល្អមាំមួន"

- សូមក្រាបថ្វាយបង្គំសម្ដេចព្រះសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គជាទីសក្ការៈ
- សម្ដេច ឯកឧត្ដម លោកជំទាវ លោក លោកស្រីបងប្អូនជនរួមជាតិទាំងអស់ជាទីស្នេហា!

ក្នុងឱកាសដ៏មហោឡារិកនៃការប្រារព្ធខួប **ទិវាជាតិអាហារូបត្ថម្ភ លើកទី៤** ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមសម្ដែងនូវមនោសញ្ចេតនារីករាយ និងគាំទ្រយ៉ាងខ្លាំងក្លាចំពោះក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិលទាំងអស់ ដែលបានរៀបចំទិវាជាតិអាហារូបត្ថម្ភដ៏មានសារៈសំខាន់នេះឡើង និងសូមថ្លែងនូវសារលិខិតថ្វាយ និងប្រគេនព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ ជូនបងប្អូនជនរួមជាតិទាំងអស់ អំពីឆន្ទៈ និងបុព្វហេតុរបស់រាជរដ្ឋាភិបាលក្នុងការបន្ដលើកកម្ពស់វិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា។ ការប្រារព្ធទិវាជាតិអាហារូបត្ថម្ភនេះ គឺក្នុងគោលបំណងអប់រំ និងលើកកម្ពស់ការយល់ដឹងជាសាធារណៈឱ្យបានទូលំទូលាយនៅទូទាំងប្រទេសអំពីសារៈសំខាន់នៃអាហារូបត្ថម្ភ និងលើកទឹកចិត្តដល់បងប្អូនជនរួមជាតិឱ្យចូលរួមអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាលដើម្បីកាត់បន្ថយភាពក្រីក្រ រក្សាកំណើនសេដ្ឋកិច្ច និងធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភសម្រាប់ជនកម្ពុជាគ្រប់រូប។

សន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺជាវិស័យមួយប្រទាក់ក្រឡាគ្នាដ៏មានសារៈសំខាន់ក្នុងការចូលរួមចំណែកដល់ការអភិវឌ្ឍធនធានមនុស្ស និងសេដ្ឋកិច្ចជាតិដែលនាំឱ្យមានភាពសំបូររុងរឿង និងសមធម៌សង្គម។ ដើម្បីសម្រេចបាននូវការងារដ៏មានសារៈសំខាន់នេះ រាជរដ្ឋាភិបាលបានសហការជាមួយតួអង្គពាក់ពន្ធ័នានា ដោយផ្ដោតការយកចិត្តទុកដាក់ទៅលើការអន្តរាគមន៍ និងការវិនិយោគនៅក្នុងវិស័យកសិកម្ម សុខាភិបាល អប់រំ អភិវឌ្ឍន៍ជនបទ ការគ្រប់គ្រងធនធានទឹក យ៉េនឌ័រ កិច្ចគាំពារសង្គម ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ និងវិស័យពាក់ព័ន្ធផ្សេងៗទៀត។ ដោយឈរលើស្មារតីនេះ ទិវាជាតិអាហារូបត្ថម្ភតែងតែជ្រើសរើសយកប្រធានបទផ្សេងៗគ្នា ជារៀងរាល់ឆ្នាំ ដើម្បីបំផុសស្មារតីយកចិត្តទុកដាក់ក្នុងការសហការគ្នា រវាងវិស័យពាក់ព័ន្ធទាំងនោះ។ ទិវាជាតិអាហារូបត្ថម្ភ លើកទី ៤ ឆ្នាំនេះ ត្រូវបានផ្ដោតសំខាន់លើប្រធានបទ **"ផលិត និងបរិភោគអាហារចម្រុះសម្បូរជីវជាតិដើម្បីសុខភាពល្អមាំមួន"** ជាប្រធានបទដែលបង្ហាញពីសារៈសំខាន់របស់វិស័យ

កសិកម្មក្នុងការចូលរួមចំណែកលើកកម្ពស់អាហារូបត្ថម្ភដោយសហការជាមួយវិស័យសុខាភិបាល និងវិស័យអប់រំ ដែលវិស័យកសិកម្មមានតួនាទីចម្បងក្នុងការធានាបាននូវសន្តិសុខស្បៀង ធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភ បង្កើនការនាំចេញកសិផល បង្កើតការងារ និងបង្កើនប្រាក់ចំណូលដើម្បីលើកកម្ពស់ជីវភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាកសិករ។ ផ្អែកតាមស្មារតីនេះ ខ្ញុំសូមអំពាវនាវដល់ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជនឱ្យបន្តកិច្ចសហការជាមួយរាជរដ្ឋាភិបាល ដើម្បីអនុវត្តនូវយុទ្ធសាស្ត្រជាតិ ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨ ផែនការសកម្មភាពជាតិ ស្តីពីការកាត់បន្ថយភាពស្រេកឃ្លាននៅកម្ពុជាឱ្យដល់កម្រិតសូន្យត្រឹមឆ្នាំ ២០២៥ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨ និងផែនការយុទ្ធសាស្ត្រតាមវិស័យដទៃទៀតដែលពាក់ពន្ធ័នឹងវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដើម្បីលើកស្ទួយគុណភាពជីវិត ដោយសំដៅធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋកម្ពុជាគ្រប់រូបមានលទ្ធភាពផ្នែករូបវន្ត សង្គម និងសេដ្ឋកិច្ចប្រសើរជាងមុខ ក្នុងការទទួលបានស្បៀងអាហារគ្រប់គ្រាន់ ប្រកបដោយសុវត្ថិភាព និងសម្បូរដោយសារជាតិចិញ្ចឹម ដើម្បីធ្វើឱ្យជីវិតរស់នៅរបស់ប្រជាពលរដ្ឋយើងមានសុខភាពល្អ និងមានផលិតភាពការងារខ្ពស់ ។

ជនរួមជាតិទាំងអស់ជាទីស្នេហា!

ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ កម្ពុជាបានឆ្លងកាត់ការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ ទាំងក្នុងទិដ្ឋភាពនយោបាយ សន្តិសុខ សេដ្ឋកិច្ច និងសង្គម។ កម្ពុជាបានក្លាយទៅជាកោះសន្តិភាព និងជាគោលដៅដ៏ល្បីល្បាញមួយ សម្រាប់ភ្ញៀវទេសចរណ៍ក្នុងតំបន់ និងពិភពលោក។ កម្ពុជាបានក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប និងត្រូវបានគេចាត់ទុកជាកូនខ្លាសេដ្ឋកិច្ចថ្មីនៅអាស៊ី ដែលមានកំណើនដ៏រឹងមាំពោលគឺក្នុងអត្រាជាមធ្យម៧,៧%ក្នុងមួយឆ្នាំ ក្នុងរយៈពេលជាង២ទសវត្សរ៍កន្លងមក ហើយកម្ពុជារំពឹងថានឹងបន្តរក្សាបាននូវអត្រាកំណើនមធ្យមប្រចាំឆ្នាំក្នុងរង្វង់៧%ក្នុងរយៈពេលមធ្យមខាងមុខ ដែលប្រការនេះបង្ហាញពីវឌ្ឍនភាពក្នុងការធ្វើពិពិធកម្មវិស័យនានា ដើម្បីជួយជំរុញកំណើនសេដ្ឋកិច្ច និងលើកស្ទួយជីវភាពប្រជាជន។ ដោយឡែកស្ថានភាពសន្តិសុខស្បៀងមានភាពល្អប្រសើរជាលំដាប់ ដោយកម្ពុជាបានផលិតស្រូវលើសជាង៤លានតោន គិតជាអង្ករជាង៣លានតោនក្នុងមួយឆ្នាំៗ តែនេះមិនមែនមានន័យថាស្ថានភាពអាហារូបត្ថម្ភមាតា និងកុមារមានភាពល្អប្រសើរឡើងនោះទេ គឺអាហារូបត្ថម្ភមានភាពប្រសើរឡើង គឺអាស្រ័យដោយរបបអាហារចម្រុះ និងគុណភាពនៃអាហារ ការផ្គត់ផ្គង់អាហារនៅក្នុងគ្រួសារ ការផ្លាស់ប្តូរទម្លាប់ទទួលទានអាហារ សមត្ថភាពអ្នកថែទាំកុមារ ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ព្រមទាំងការទទួលបានសេវាសុខភាពល្អ។

បញ្ហាកង្វះអាហារូបត្ថម្ភ និងលើសអាហារូបត្ថម្ភគឺជាបន្ទុកមួយរបស់រាជរដ្ឋាភិបាលដែលត្រូវគិតគូរ និងដាក់ចេញយុទ្ធសាស្ត្រច្បាស់លាស់ដើម្បីដោះស្រាយ បញ្ហានេះបានបង្ហាញជាសញ្ញានូវបម្រែបម្រួលសេដ្ឋកិច្ច និងជាការព្យាករណ៍ប្រាប់នូវបញ្ហាប្រឈមកាន់តែធំធេងថែមទៀតដែលនឹងអាចកើតឡើងនាពេលអនាគត រួមទាំងបញ្ហាជំងឺមិនឆ្លងផងដែរ។ កង្វះអាហារូត្ថម្ភក្នុងវ័យដំបូងរបស់កុមារ មិនត្រឹមតែប៉ះពាល់ដល់សុខភាព និងមរណភាពរបស់កុមារប៉ុណ្ណោះទេ ប៉ុន្តែវានឹងប៉ះពាល់ដល់ការរីកចំរើនខាងសតិបញ្ញារបស់កុមារ ការសិក្សា

រៀនសូត្រ និងផលិតភាពការងារនាពេលអនាគត ហើយលទ្ធផលនេះគឺប៉ះពាល់មិនត្រឹមតែទៅលើសេដ្ឋកិច្ចគ្រួសារប៉ុណ្ណោះទេ ប៉ុន្តែបានប៉ះពាល់ដល់សេដ្ឋកិច្ចជាតិទាំងមូល។

ក្នុងស្មារតីខាងលើខ្ញុំសូមអំពាវនាវដល់គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជនទាំងអស់ ដែលកំពុងធ្វើការលើវិស័យអាហារូបត្ថម្ភ ត្រូវពង្រឹង និងពង្រីកយុទ្ធនាការអប់រំ ផ្សព្វផ្សាយតាមគ្រប់មធ្យោបាយដើម្បីលើកទឹកចិត្តបងប្អូនប្រជាកសិករដែលមានលទ្ធភាពឲ្យចូលរួម (ទី១).ផលិតគ្រប់មុខដំណាំជាលក្ខណៈគ្រួសារ ឬ ជាសហគមន៍ ដូចជាសួនបន្លែតាមគ្រួសារ សួនបន្លែតាមសាលារៀន ឬតាមវត្តអារាមនានា ដើម្បីបង្កើនទាំងបរិមាណគុណភាព និងធានាឲ្យមានប្រភពស្បៀងអាហារចម្រុះមានសុវត្ថិភាពតាមរយៈការជំរុញការកសាងហេដ្ឋារចនាសម្ព័ន្ធលើដីស្រែចំការ សំដៅបង្កើនការធ្វើកសិកម្មចម្រុះ ការអនុវត្តកសិកម្មល្អ ដោយមិនត្រូវទុកដីឱ្យនៅទំនេរ, (ទី២).ជំរុញលើកកម្ពស់ការចិញ្ចឹមសត្វឲ្យកាន់តែទូលំទូលាយ និងមាននិរន្តរភាព ដើម្បីធានាការផ្គត់ផ្គង់សាច់សត្វ ធានាសុវត្ថិភាពចំណីអាហារ តាមរយៈការត្រួតពិនិត្យអនាម័យ និងភោគ្គតាមអនាម័យ, (ទី៣). បង្កើនការការពារ និងអភិរក្សធនធានជលផល និងជំរុញការអភិវឌ្ឍវារីវប្បកម្ម ដើម្បីធានាឲ្យបាននូវនិរន្តរភាពធនធានជលផល ព្រមទាំងកែលម្អគុណភាព និងសុវត្ថិភាពផលិតផលជលផលសម្រាប់ការប្រើប្រាស់ក្នុងស្រុក និងនាំចេញ, (ទី៤). ជំរុញលើកទឹកចិត្តឲ្យប្រជាពលរដ្ឋបរិភោគអាហារធម្មជាតិចម្រុះមុខ ដែលមាននៅក្នុងមូលដ្ឋានដែលសម្បូរទៅដោយសារជាតិចិញ្ចឹម ពិសេសបន្លែ ផ្លែឈើ ត្រី ស៊ុត និងសាច់ឲ្យបានកាន់តែច្រើនថែមទៀត ដើម្បីទទួលបានអាហារូបត្ថម្ភល្អមានសុខភាពល្អ និងជីវិតប្រសើរថ្ងៃថ្លា។

មុននឹងបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំ សង្ឃឹមយ៉ាងមុតមាំថាការប្រារព្ធ **ទិវាជាតិអាហារូបត្ថម្ភ លើកទី៤** នឹងពង្រឹងពង្រីកឆន្ទៈរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល វិស័យឯកជន និងបងប្អូនជនរួមជាតិទាំងអស់ឲ្យកាន់តែយកចិត្តទុកដាក់ថែមមួយកម្រិតទៀត ក្នុងការចូលរួមជាមួយនឹងរាជរដ្ឋាភិបាលក្នុងបុព្វហេតុឆ្ពោះទៅសម្រេចឲ្យបាននូវគោលដៅទី ២ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចិរភាព គឺបញ្ចប់ភាពអត់ឃ្លានសម្រេចបានសន្តិសុខស្បៀង និងកែលម្អអាហារូបត្ថម្ភ និងលើកកម្ពស់កសិកម្មដែលមាននិរន្តរភាពនៅកម្ពុជា ។

ជាទីបញ្ចប់ដើម្បីចូលរួមអបអរសាទរ **ទិវាជាតិអាហារូបត្ថម្ភ ៦ វិច្ឆិកា** និងចូលរួមសប្បាយរីករាយជាមួយបងប្អូនជនរួមជាតិក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងអកអំបុក សំពះព្រះខែ ទូលព្រះបង្គំខ្ញុំព្រះករុណាខ្ញុំ សូមថ្វាយព្រះពរសម្តេចព្រះសង្ឃរាជទាំងពីរគណៈ ប្រគេនពរព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងជូនពរបងប្អូនជនរួមជាតិទាំងអស់ សូមបានប្រកបដោយពុទ្ធពរទាំងប្រាំប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ បដិភាណៈ** កុំបីឃ្លៀងឃ្លាតឡើយ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៧

**ហ៊ុន សែន**